**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃ លេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា និងអន្តរភាពអនុវត្តរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងប្រព័ន្ធស្បៀងបម្រុងកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៥ មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៨ មាត្រា២២ មាត្រា២៣ និងមាត្រា២៨ នៃអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣ ៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញសេចក្តីសម្រេចលេខ ០៦ សសរ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា
- បានឃើញប្រកាសលេខ ៦២២ សហវ.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបែងចែកភារកិច្ចរបស់អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១._**

លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា ដែលសរសេរអក្សរកាត់ថា លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការ **ប.ស.ប.ក.**។

ដើម្បីធានាបាននូវនិរន្តរភាពនិងសង្គតិភាពនៃកិច្ចដំណើរការការងារ សមាសភាពដំបូងរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីបុគ្គលិកដែលធ្លាប់បម្រើការងារជូនគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ និងគម្រោងឧបត្ថម្ភស្បៀងបន្ទាន់-ហិរញ្ញប្បទានបន្ថែម ដែលមានបទពិសោធន៍ជួយប្រព័ន្ធស្បៀងបម្រុងកម្ពុជាកន្លងមក។ សមាសភាពនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** អាចត្រូវធ្វើការជ្រើសរើសបន្ថែម ក្នុងករណីមានតម្រូវការចាំបាច់ផ្អែកតាមទំហំការងាររបស់ខ្លួន បន្ទាប់ពីមានការឯកភាពពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២._**

លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** មានតួនាទីនិងភារកិច្ចដូចតទៅ÷

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការ **ប.ស.ប.ក.** ស្របតាមការណែនាំរបស់ប្រធានគណៈកម្មាធិការ **ប.ស.ប.ក.**
- រៀបចំ ចាត់ចែង និងធ្វើរបាយការណ៍កិច្ចប្រជុំរបស់គណៈកម្មាធិការ **ប.ស.ប.ក.**
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់នានាក្នុងកម្រិតបច្ចេកទេសជាមួយស្ថាប័នពាក់ព័ន្ធ **ប.ស.ប.ក.** និងស្ថាប័នដទៃទៀតតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពខ្ពស់នៃប្រតិបត្តិការរបស់ **ប.ស.ប.ក.**
- រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ និងការផ្សព្វផ្សាយនានាដែលចាំបាច់ ដើម្បីបង្កើនសមត្ថភាពស្ថាប័នពាក់ព័ន្ធទៅនឹងការអនុវត្ត និងការបង្កើនប្រសិទ្ធភាព **ប.ស.ប.ក.**
- រៀបចំរបាយការណ៍ចាំបាច់នានាស្តីពីសកម្មភាពរបស់ **ប.ស.ប.ក.** ជូនប្រធានគណៈកម្មាធិការ**ប.ស.ប.ក.** ដើម្បីពិនិត្យនិងចុះហត្ថលេខា
- គ្រប់គ្រង និងចាត់ចែងថវិកា គណនេយ្យ ហិរញ្ញវត្ថុ និងសម្ភារៈការិយាល័យរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** និងអង្គភាពអនុវត្តនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុង **ប.ស.ប.ក.**
- គ្រប់គ្រងធនធានមនុស្សរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** និងអង្គភាពអនុវត្តនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុង **ប.ស.ប.ក.**

- បំពេញការងារផ្សេងទៀតតាមការចាំបាច់ដែលប្រគល់ជូនដោយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានគណៈកម្មាធិការ **ប.ស.ប.ក.**។

**ប្រការ៣._**

លេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** បំពេញតួនាទីបន្ថែមជាអង្គភាពអនុវត្តរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្នុង **ប.ស.ប.ក.** អនុលោមតាមអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៥ មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៨ មាត្រា២២ មាត្រា២៣ និងមាត្រា២៨នៃអនុក្រឹត្យលេខ១៤៥ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា។

**ប្រការ៤._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការ **ប.ស.ប.ក.** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- កាកបាទក្រហមកម្ពុជា
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ